# ថ្ងៃកំណើត

ខ្ញុំ **សាន សុជា** កើតនៅថ្ងៃអង្គារ ៧ រោច ខែ មិគសិរ ឆ្នាំម្សាញ់ ព.ស. ២៥២០ ចុង គ.ស. ១៩៧៦ នៅទួលតាអុក ឃុំកំពង់យោល ស្រុកទ្រាំង ខេត្តតាកែវ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់លោក **ប៉ុល ពត**, ជាកូនរបស់លោកឪពុក **ទឹម ទុយ** និងអ្នកម្តាយ **អៀង ចែម** សព្វថ្ងៃទីនោះស្ថិតនៅក្នុងឃុំគោកពោធិ៍ ស្រុកបូរីជលសា ខេត្តជង្រៃល ។ សម័យនោះ គ្រួសារនេះស្ថិតនៅក្នុងពួក**អ្នកត្រៀម** និងពួក**អ្នកផ្ញើ** ហៅថា ១៧ ដោយមិនមានសមាជិកណាម្នាក់នៃគ្រួសារនេះ បានជាអ្នកពេញសិទ្ធិទេ ហើយមានការទទួលរងទុក្ខមិនខុសពីប្រជាជនទូទៅដែរ ។ **សុជាខ្ញុំ** បានកើតនៅក្នុងសង្គមមួយដ៏ខ្មៅងងឹត ឥតមានមន្ទីរពេទ្យ ឥតមានថ្នាំសង្កូវត្រឹមត្រូវឡើយ ។

បានឮមកថា ក្នុងសម័យនោះ ដោយខ្លាចប្រជាជនចូលដៃជាមួយពួកយួន **កម្មាភិបាលប៉ុល ពត** បានបំភ័យប្រជាជនថា "ពួកយួនឡើងមកវះពោះញាត់ស្មៅ អ្នកត្រូវតែរត់ទៅខាងលើ..." ប្រជាជនក៏បានភៀសខ្លួនចេញពីភូមិអស់ ។ គ្រួសារនេះក៏មានបំណងរត់ទៅនឹងគេដែរ ។ ថ្ងៃនោះអ្នកម្តាយចាប់ផ្តើមឈឺផ្ទៃ លោកឪពុកបានគ្រាហ៍អ្នកម្តាយឡើងលើរទេះ បរចេញពីភូមិ

អ្នកតាត្បាល់ បានចម្ងាយជាងមួយគីឡូម៉ែត្រ អ្នកម្ដាយឈឺពោះកាន់តែខ្លាំង មិនអាចធ្វើដំណើរទៅទៀតបាន ក៏ចូលទៅសម្រាកក្នុងខ្ទមកម្សត់មួយ នៅឯការដ្ឋានទួលតាអុក ។ ភ្លាមនោះ **សុជាខ្ញុំ**ក៏បានប្រសូតចាកផ្ទៃម្ដាយ នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ។ លោកឪពុកបានយកកង់ជិះយ៉ាងលឿនទៅអន្ទរលោកយាយ**ធួក** ជាឆ្មបដែលបានកៀសខ្លួនទៅឆ្ងាយហើយ លោកឪពុកទៅទាន់យាយហួបនៅខាងលិចវត្តគោកពោធិ៍ ។ ពេលនោះ លោកយាយ**ធួក**ប្រកែកមិនហ៊ានត្រឡប់មកជួយទេ ព្រោះខ្លាចយួនវះពោះញាត់ស្មៅ ។ លោកឪពុកចុះកាន់កង់បណ្ដើរអន្ទរលោកយាយហួប ដោយពាក្យជាដើមថា "ឲ្យតែលោកយាយទៅជួយកាត់ទងផ្ចិតកូនខ្ញុំរួច ខ្ញុំនឹងឌុបលោកយាយត្រឡប់មកឲ្យទាន់គេវិញ....." អស់រយៈចម្ងាយប្រហែលជិតកន្លះគីឡូម៉ែត្រ ទើបលោកយាយហួបព្រម ។ ទម្រាំតែលោកឪពុកឌុបឆ្មបមកដល់ **សុជាខ្ញុំ**បានដេកយំនៅលើរនាបឫស្សី អស់រយៈពេលជិតពីរម៉ោងទៅហើយ តាំងពីយំឮរហូតដល់យំលែងឮ ឯខ្លួនក៏ស្ពួតអស់ សាច់ក្បាលរលាត់ចេញឈាម ដោយកកិតនឹងរនាបឫស្សី និងក្បាលដែកគោល ។ លោកយាយហួបបានចាត់ការតាមវិធីឆ្មបបូរាណ រួចស្រេចកាលណា លោកឪពុកក៏ឌុបយាយហួបត្រឡប់ទៅកន្លែងដើម ។

*ឯជំណើងថា យួនឡើងមកវះពោះនោះ ជាជំណើងក្លែងក្លាយអស់រយៈពេល ពីរបីថ្ងៃ ប្រជាជនក៏បានត្រឡប់មកវិញ ហើយធ្វើការងារតាមការបញ្ជារបស់កម្មាភិបាល* ***ប៉ុល ពត*** *ដូចដើមវិញ ។ ចំពោះសេចក្ដីទុក្ខនៃគ្រួសារនេះ ខ្ញុំមិនចាំបាច់រៀបរាប់ទេ ព្រោះប្រជាជនស្ទើរតែទាំងអស់ ក្រៅពីកម្មាភិបាល* ***ប៉ុល ពត*** *សុទ្ធតែជួបប្រទះដូចគ្នា ។*

## គ្រួសារសុជាក្រោយថ្ងៃរំដោះ

*ក្រោយថ្ងៃរំដោះ គ្រួសារនេះ បានត្រឡប់ទៅសាងគេហដ្ឋាននៅភូមិអ្នកតាត្បាល់វិញ និងចាប់ផ្ដើមធ្វើកសិកម្ម និងនេសាទកម្មដូចគ្រួសារដទៃដែរ ប៉ុន្ដែជីវភាពគ្រួសារមិនរីកចម្រើនទេ ។ ខ្ញុំចាំបានថាធ្លាប់បានបរិភោគបាយដាំលាយជាមួយនឹងពោតក្រហម ដែលលោកឪពុកយកស្ករទៅដូរនៅឯស្រុកកោះធំ ខេត្តកណ្ដាល ។*

| | |
|---|---|
| រឿងរ៉ាវជីវិតមិនពិតប្រាកដ | មិនអាចកំណត់ដោយខ្លួនឯងបាន |
| គ្រប់គ្នាសុទ្ធតែចង់រុងរឿងថ្កាន | តែមិនអាចបានតាមប្រាថ្នាឡើយ ។ |
| ជួនលិចជួនឡើងតាមតែវាសនា | ដែលកម្មបានចាររួចស្រេចមកហើយ |
| ត្រូវតែទទួលគេចមិនរួចឡើយ | តែដល់ពេលហើយគ្មានអ្នកជួយបាន ។ |
| បើចង់កែប្រែខ្សែរឿងជីវិត | ត្រូវមានគំនិតកុំភ្លឹកភ្លេចប្រាណ |
| ត្រូវខំសូត្ររៀនសាងកម្មកល្យាណ | ប្រាកដជាបានអនាគតរុងរឿង ។ |